**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

លេខ : ......១៥១៤ ប.ទ.................... ថ្ងៃ ពុធ ២រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដាក់ឱ្យដំណើរការប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម (EIRS)

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (**ក.ប.ទ.**) សូមជម្រាបជូនសាធារណជនទាំងអស់ជ្រាបថា ដើម្បីចូលរួមកាត់បន្ថយនិងទប់ស្កាត់ការនាំចូល **ទូរសព្ទចល័ត ឬឧបករណ៍ទូរគមនាគមន៍ដែលប្រើស៊ីម ("ឧបករណ៍ប្រើស៊ីម")** ក្រៅផ្លូវការ សំដៅការពារផលប្រយោជន៍និងសុវត្ថិភាពអ្នកប្រើប្រាស់ ពង្រឹងគុណភាពសេវាទូរគមនាគមន៍ លើកកម្ពស់ការប្រកួតប្រជែងដោយស្មោះត្រង់ និងកំណត់អត្តសញ្ញាណនៃទូរសព្ទចល័ត ឬឧបករណ៍ប្រើស៊ីម **ក.ប.ទ.** នឹងដាក់ឱ្យដំណើរការ **ប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម (Equipment Identity Registration System - EIRS)** ចាប់ពី **ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៦** នេះតទៅ។

នៅក្នុង **ដំណាក់កាលដំបូង** នៃការដាក់ឱ្យដំណើរការនេះ ប្រព័ន្ធ EIRS នឹងបើកឱ្យសាធារណជនប្រើប្រាស់ "**មុខងារពិនិត្យស្ថានភាពលេខអាយម៉ី (International Mobile Equipment Identity - IMEI)" ដោយឥតគិតថ្លៃ** ក្នុងនោះ ១) អាចត្រួតពិនិត្យអំពីទូរសព្ទចល័ត ឬឧបករណ៍ប្រើស៊ីមនៅលើទីផ្សារ ពិតជាមានស្តង់ដានិងមានគុណភាព មុននឹងសម្រេចចិត្តទិញប្រើប្រាស់ និង ២) អាចត្រួតពិនិត្យអំពីស្ថានភាពទូរសព្ទចល័ត ឬឧបករណ៍ប្រើស៊ីមដែលខ្លួនកំពុងប្រើប្រាស់។ ការពិនិត្យស្ថានភាពលេខអាយម៉ី អាចធ្វើតាមវិធីសាស្ត្រដូចខាងក្រោម៖

### ក. ការស្វែងរកលេខអាយម៉ីដែលមានចំនួន ១៥ ខ្ទង់ តាមវិធីណាមួយក្នុងចំណោមវិធីទាំង ៣ ខាងក្រោម៖

- ការចុចលេខកូដ ***#06#** នៅលើផ្ទាំងលេខ (Keypad) របស់ទូរសព្ទចល័ត ឬឧបករណ៍ប្រើស៊ីម។
- ការចូលទៅកាន់មុខងារ "**ការកំណត់ (Settings)**" នៃទូរសព្ទចល័ត ឬឧបករណ៍ប្រើស៊ីម។
- ការពិនិត្យលេខអាយម៉ីនៅលើប្រអប់ដើម (Original Box) របស់ទូរសព្ទចល័ត ឬឧបករណ៍ប្រើស៊ីម។

### ខ. ការពិនិត្យស្ថានភាពលេខអាយម៉ី តាមជម្រើសណាមួយក្នុងចំណោមជម្រើសទាំង ៤ ខាងក្រោម៖

- ការចូលទៅកាន់វេបសាយ **www.eirs.gov.kh**។
- ការប្រើប្រាស់កម្មវិធីទូរសព្ទចល័ត **IMEI KH**។
- ការប្រើ **សេវាយូ.អេស.អេស.ឌី (USSD)** តាមរយៈការចុច **លេខកូដ *១២០៥#** រួចចុចបញ្ជូន និងអនុវត្តតាមការណែនាំ។
- ការប្រើ **សេវាសារខ្លី (SMS)** តាមរយៈការវាយ **CHK<ដកឃ្លា><លេខអាយម៉ី១៥ខ្ទង់>** រួចចុចបញ្ជូនទៅកាន់លេខ ១២០៥។

## គ. លទ្ធផលនៃការពិនិត្យស្ថានភាពលេខអាយម៉ី មាន ៤ ប្រភេទ គឺ៖

- **លេខអាយម៉ីត្រឹមត្រូវ និងបានដំណើរការ** មានន័យថា លេខអាយម៉ីនេះត្រឹមត្រូវ ហើយបានដំណើរការលើបណ្ដាញទូរសព្ទចល័តនៅកម្ពុជាជាធម្មតា។
- **លេខអាយម៉ីត្រឹមត្រូវ និងមិនទាន់បានដំណើរការ** មានន័យថា លេខអាយម៉ីនេះត្រឹមត្រូវ ប៉ុន្តែមិនទាន់បានដំណើរការលើបណ្ដាញទូរសព្ទចល័តនៅកម្ពុជានៅឡើយ។
- **លេខអាយម៉ីមិនត្រឹមត្រូវ និងបានដំណើរការ** មានន័យថា លេខអាយម៉ីនេះមិនត្រឹមត្រូវ ហើយបានដំណើរការលើបណ្ដាញទូរសព្ទចល័តនៅកម្ពុជាជាធម្មតា។
- **លេខអាយម៉ីមិនត្រឹមត្រូវ និងមិនទាន់បានដំណើរការ** មានន័យថា លេខអាយម៉ីនេះមិនត្រឹមត្រូវ ហើយមិនទាន់បានដំណើរការលើបណ្ដាញទូរសព្ទចល័តនៅកម្ពុជានៅឡើយ។

**សូមបញ្ជាក់ផងដែរថា** គ្រប់ទូរសព្ទចល័ត ឬឧបករណ៍ប្រើស៊ីមទាំងអស់ដែលកំពុងប្រើប្រាស់នៅក្នុងបណ្ដាញទូរសព្ទចល័តនៅកម្ពុជា គឺនៅតែអាចដំណើរការនិងប្រើប្រាស់បានជាធម្មតា បើទោះជាលទ្ធផលនៃការពិនិត្យស្ថានភាពលេខអាយម៉ី បានបង្ហាញអំពីស្ថានភាពណាមួយក៏ដោយ។

ទន្ទឹមនឹងនេះដែរ **ន.ប.ទ.** សូមអំពាវនាវដល់សាធារណជនទាំងអស់ សូមចៀសវាងការទិញទូរសព្ទចល័ត ឬឧបករណ៍ប្រើស៊ីមណាដែលបានបង្ហាញលទ្ធផលថា "**លេខអាយម៉ីមិនត្រឹមត្រូវ**" យកមកប្រើប្រាស់ ពីព្រោះថា ទូរសព្ទចល័ត ឬឧបករណ៍ប្រើស៊ីមនោះ អាចជាឧបករណ៍ដែលគ្មានស្តង់ដានិងគ្មានគុណភាព ឬជាឧបករណ៍ក្លែងក្លាយ។ **ន.ប.ទ.** សង្ឃឹមយ៉ាងមុតមាំថា សាធារណជននឹងចូលរួមប្រើប្រាស់ប្រព័ន្ធ EIRS ដើម្បីចូលរួមកាត់បន្ថយ ទប់ស្កាត់ និងលុបបំបាត់ការប្រើប្រាស់ទូរសព្ទចល័ត ឬឧបករណ៍ប្រើស៊ីមដែលមានលេខអាយម៉ីមិនត្រឹមត្រូវ។

សាធារណជនអាចស្កេន QR Code ខាងក្រោម ដើម្បីទទួលបានការណែនាំនិងព័ត៌មានលំអិតអំពីការប្រើប្រាស់មុខងារក្នុងជំហានដំបូងនៅក្នុងប្រព័ន្ធ EIRS នេះ ឬទូរសព្ទទៅកាន់លេខ ១២០៥ ដោយឥតគិតថ្លៃ រៀងរាល់ម៉ោងធ្វើការ។

អាស្រ័យហេតុនេះ សូមសាធារណជនទាំងអស់មេត្តាជ្រាប និងចូលរួមប្រើប្រាស់ឱ្យបានទូលំទូលាយ។

**សូមស្កេន QR Code ខាងក្រោម ដើម្បី៖**

**ស្វែងរកព័ត៌មានបន្ថែមតាមរយៈវេបសាយ**

**ទាញយកកម្មវិធីទូរសព្ទចល័ត**

**ទាញយកសៀវភៅពិនិត្យស្ថានភាពឧបករណ៍**